# 7 សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារ

# ការចាក់ដីបំពេញ

ដីចាក់បំពេញដីគឺប្រើវត្ថុធាតុណាមួយដើម្បីចាក់បំពេញលើកកំពស់ដីឲ្យកាន់តែខ្ពស់ឡើងសំរាប់មូលហេតុណាមួយ។ វត្ថុធាតុដែលប្រើដើម្បីចាក់បំពេញដី ជាទូទៅមានរួមទាំងដីផ្នែកលើ ដីឥដ្ឋ និងដីខ្សាច់។

## ហេតុអ្វីបានជាការចាក់ដីបំពេញគឺជាបញ្ហា?

ការចាក់ដីបំពេញអាចបណ្តាលឲ្យមានបញ្ហាទាំងឡាយដូចជា:

- ជាតិពុលគីមីនៃកសិកផលរបស់លោកអ្នក តាមរយៈជាតិពុលនៃដី និងទឹករបស់លោកអ្នក
- ការផ្លាស់ប្តូរដល់ប្រព័ន្ធបង្ហូរទឹក និងព្រែកទាំងពួងរបស់លោកអ្នក
- ទឹកជំនន់
- ការខូចខាតដល់ទីដីធ្លីរបស់អ្នកជិតខាងលោកអ្នក
- ការច្រោះដី និងភាពកករ
- បញ្ហាដុះនៃរុក្ខជាតិតូចៗឥតប្រយោជន៍
- ការខូចខាតដល់ដីគុម្ពោត
- ការមានជាតិពុលនៃទឹកខ្លែង ដោយសារតែដីចាក់បំពេញដែលពុំមានការអនុញ្ញាត។



NSW DPI, Virginia Brunton

**ដីចាក់បំពេញគឺជាបញ្ហាមួយយ៉ាងធ្ងន់ធ្ងរ ហើយជាទូទៅសាលាក្រុងមិនជំរុញទឹកចិត្តឲ្យធ្វើឡើយ។ សូមគិតដោយប្រុងប្រយ័ត្ន អំពីមូលហេតុរបស់លោកអ្នកក្នុងការប្រើដីចាក់បំពេញ។**



NSW DPI, Steven Honeywood

ប្រសិនបើលោកអ្នកកំពុងគ្រោងប្រើដីចាក់បំពេញ ជាមួយនឹងវត្ថុធាតុដែលមានរួចហើយនៅក្នុងបរិវេណដីធ្លីរបស់លោកអ្នក សូមទាក់ទងជាមួយសាលាក្រុងរបស់លោកអ្នកដើម្បីទទួលឱវាទ ដ្បិតអីលោកអ្នកទំនងជាត្រូវការច្បាប់អភិវឌ្ឍន៍ដើម្បីធ្វើការនេះ។

ជាទូទៅ គេត្រូវការច្បាប់អភិវឌ្ឍន៍ប្រសិនបើការចាក់បំពេញដី:

១) មានជំរៅលើសពី១ម៉ែត្រ ជ្រៅជាងជំរៅដែលមានពីមុន

២) មានផ្ទៃក្រឡា១០០ម៉ែត្រការ៉េ ឬលើសពីនេះ

៣) មានចម្ងាយ៤០ម៉ែត្រពីប្រឡាយទឹក។

ប្រសិនបើលោកអ្នកកំពុងគ្រោងប្រើវត្ថុធាតុពីដីធ្លីមួយទៀត លោកអ្នកនឹងត្រូវការអនុញ្ញាតយល់ព្រមជាលាយលក្ខណ៍អក្សរពីសាលាក្រុង។ ប្រសិនបើលោកអ្នកពុំមានការអនុញ្ញាតយល់ព្រមជាលាយលក្ខណ៍អក្សរទេ លោកអ្នកនឹងទទួលការផាកពិន័យយ៉ាងធ្ងន់ធរនៅក្រោមច្បាប់បរិដ្ឋានរដ្ឋញូវសៅវែល។

**សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារនេះ** គឺជាផ្នែកនៃលំដាប់ព័ត៌មានគ្រោងឡើងដើម្បីជួយដល់អ្នកដំណាំដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទ TIS លេខ 131 450។

គំរោងការនេះបានទទួលការផ្គត់ផ្គង់ពីរដ្ឋាភិបាលរដ្ឋញូវសៅវែល តាមរយ: មូលនិធិបរិដ្ឋានរបស់ខ្លួន (Environmental Trust)។

ព័ត៌មានដែលចុះនៅក្នុងការចុះផ្សាយនេះសំអាងទៅលើចំណេះដឹង និងការដឹងយល់នៅចំពេលកំពុងសរសេរ (ខែវិច្ឆិកា ឆ្នាំ២០០៧)។ ទោះជាយ៉ាងណាក្តី ដោយព្រោះតែការចំរើនលើចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកប្រាប់ពីសេចក្តីត្រូវការដើម្បីឲ្យបានប្រាកដថាព័ត៌មានដែលគេពឹងផ្អែកនោះគឺទាន់ពេលថ្មីៗ ហើយត្រូវឆែកមើលព័ត៌មានបច្ចុប្បន្នជាមួយភ្នាក់ងារសមស្របនៃក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល ឬជាមួយអ្នកប្រឹក្សាឯករាជ្យនៃអ្នកប្រើប្រាស់ព័ត៌មាននេះ។

NSW DEPARTMENT OF PRIMARY INDUSTRIES

NSW Environmental TRUST